ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

# នាយករដ្ឋមន្ត្រីតួគី អញ្ជើញសម្តេចតេជោនាយករដ្ឋមន្ត្រី បំពេញទស្សនកិច្ចផ្លូវការនៅតួគី

*********

នៅក្នុងជំនួបសម្តែងការគួរសមរបស់លោកជំទាវ Ayda Ünlü ឯកអគ្គរដ្ឋទូតរបស់តួគីប្រចាំកម្ពុជា នៅព្រឹកថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៨ ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានធ្វើការកត់សម្គាល់ចំពោះការកើនឡើងក្នុងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ បន្ទាប់ពីការបើកស្ថានទូតតួគី នៅទីក្រុងភ្នំពេញ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៣។ ឯកឧត្តមបានសម្តែងក្តីសង្ឃឹមថាលោកជំទាវនឹងរួមចំណែកក្នុងការពង្រឹង និងពង្រីកបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការទ្វេភាគី ហើយបានអះអាងថានឹងផ្តល់នូវកិច្ចសហការ និងការគាំទ្រពេញលេញដល់បេសកកម្មរបស់លោកជំទាវនៅកម្ពុជា។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកឡើងអំពីការកើនឡើងនូវការផ្លាស់ប្តូរពាណិជ្ជកម្មទ្វេភាគី ប៉ុន្តែបរិមាណនៅមិនទាន់សមស្របនឹងសក្តានុពលសេដ្ឋកិច្ចរបស់ប្រទេសទាំងពីរនៅឡើយ ហើយឯកឧត្តមបានជំរុញឲ្យមានការខិតខំបន្ថែមទៀតរបស់ភាគីទាំងពីរ ដើម្បីបង្កើនទំហំនៃការផ្លាស់ប្តូរពាណិជ្ជកម្ម។ ក្នុងន័យនេះ ឯកឧត្តមទេសរដ្ឋមន្ត្រីបានស្នើឲ្យតួគីធ្វើការកោះប្រជុំគណៈកម្មការចម្រុះសេដ្ឋកិច្ច នៅឆ្នាំ២០១៨នេះ ដើម្បីពិភាក្សាលើការស្វែងរកវិធីបង្កើនកិច្ចសហប្រតិបត្តិកាលើផ្នែកសេដ្ឋកិច្ច រវាងប្រទេសទាំងពីរ។ ឯកឧត្តមក៏បានលើកឡើងអំពីសំណើរបស់កម្ពុជា កោះប្រជុំកិច្ចពិគ្រោះនយោបាយរវាងក្រសួងការបរទេសនៃប្រទេសទាំងពីរ នៅខែឧសភាខាងមុខ។

លោកជំទាវឯកអគ្គរដ្ឋទូត បានជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រីអំពីការផ្តាំផ្ញើសួរសុខទុក្ខ និងការត្រៀមរបស់ឯកឧត្តមរដ្ឋមន្ត្រីការបរទេសតួគី ទទួលស្វាគមន៍ដំណើរទស្សនកិច្ចផ្លូវការរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី នៅប្រទេសតួគី ក្នុងអនាគតខាងមុខ និងអំពីសំណើរបស់ឯកឧត្តម Binali Yildirim នាយករដ្ឋមន្ត្រីតួគី អញ្ជើញ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា បំពេញទស្សនកិច្ចផ្លូវការ នៅប្រទេសតួគី ក្នុងឆ្នាំ២០១៨នេះ។ លោកជំទាវក៏បានជម្រាបថាតួគីមានគំរោងកោះប្រជុំគណៈកម្មការចម្រុះសេដ្ឋកិច្ច នៅក្នុងខែកញ្ញា បន្ទាប់ពីការបោះឆ្នោតទូទៅ នៅប្រទេសតួគី នាថ្ងៃទី២៤ ខែមិថុនាខាងមុខនេះ។

ឯកឧត្តមទេសរដ្ឋមន្ត្រី និងលោកជំទាវឯកអគ្គរដ្ឋទូត ក៏បានពិភាក្សាអំពីពេលវេលាសំរាប់ទស្សនកិច្ចរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ដែលគួរធ្វើឡើងក្នុងឆមាសទី២ ឆ្នាំ២០១៨ ហើយនិងទស្សនកិច្ចរបស់ឯកឧត្តមទេសរដ្ឋមន្ត្រីផ្ទាល់។ ឯកឧត្តមក៏បានស្នើភាគីទាំងពីរជំរុញការពិភាក្សាលើឯកសារ និងកិច្ចព្រមព្រៀងទាំងឡាយ ដើម្បីឈានទៅធ្វើការចុះហត្ថលេខាក្នុងឱកាសទស្សនកិច្ចរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី។

លោកជំទាវឯកអគ្គរដ្ឋទូត បានគូសបញ្ជាក់ថា ឆ្លើយតបនឹងសំណូមពររបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ឲ្យមានជំនួយរបស់តួគីលើការបោសសំអាតមីននៅកម្ពុជា តួគីគ្រោងបញ្ជូនក្រុមការងារមួយមកកម្ពុជា ក្នុងខែឧសភាខាងមុខ ដើម្បីធ្វើការពិនិត្យជាក់ស្តែង និងពិភាក្សាជាមួយភាគីពាក់ព័ន្ធកម្ពុជា អំពីលទ្ធភាពក្នុង

ការផ្តល់ជំនួយលើបញ្ហានេះ។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានសំដែងក្តីរីករាយចំពោះការឆ្លើយតបជាវិជ្ជមាននេះ ហើយបានឆ្លៀតឱកាសលើកឡើងពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល និងលទ្ធផលដ៏ធំធេងក្នុងការងារបោសសំអាតមីននៅកម្ពុជាបានជាង ១.៦០០គ.ម² ហើយទន្ទឹមនឹងនោះបានគូសបញ្ជាក់ថាបញ្ហាមីននៅតែជាឧបសគ្គដ៏សំខាន់នៃការអភិវឌ្ឍន៍ជនបទ។

នៅក្នុងជំនួបនេះដែរ ឯកឧត្តមទេសរដ្ឋមន្ត្រី បានថ្លែងអំណរគុណតួគី ចំពោះការប្រកាន់ជំហរគោរពអធិបតេយ្យភាព និងឯករាជ្យរបស់កម្ពុជា ហើយបានចាត់ទុកការចាត់វិធានការនានារបស់អាជ្ញាធរមានសមត្ថកិច្ចកម្ពុជា សំដៅពង្រឹងនីតិរដ្ឋ ការពារសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍ ជាបញ្ហាផ្ទៃក្នុងរបស់កម្ពុជា។

ជំនួបបានបញ្ចប់ក្នុងបរិយាកាសស្និទ្ធស្នាល និងយោគយល់គ្នា។

ថ្ងៃ សុក្រ ៦កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៨